ព្រះរាជក្រឹត្យ

នស/រកត/១១២៣/ ២៣៤១

ស្ដីពី

ការបង្កើត ការរៀបចំ និងកិច្ចដំណើរការរបស់
អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៣

ត្រាស់បង្គាប់

ជំពូកទី១
បទប្បញ្ញត្តិទូទៅ

**មាត្រា១ ..**

ព្រះរាជក្រឹត្យនេះ កំណត់អំពីការបង្កើត ការរៀបចំ និងកិច្ចដំណើរការរបស់អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដើម្បីជាយន្តការបំពេញបន្ថែមឱ្យប្រព័ន្ធដោះស្រាយវិវាទនៅព្រះរាជាណាចក្រកម្ពុជា សំដៅលើកកម្ពស់គុណភាព ប្រសិទ្ធភាព និងភាពឆាប់រហ័សនៃការដោះស្រាយវិវាទ តាមរយៈការសម្រុះសម្រួលដោះស្រាយក្រៅប្រព័ន្ធតុលាការ ក្នុងគោលបំណងជួយកាត់បន្ថយការកកស្ទះសំណុំរឿងនៅតាមសាលាជម្រះក្ដី បង្កើតសេវាដោះស្រាយវិវាទឱ្យកាន់តែទៅកៀកនឹងប្រជាពលរដ្ឋនៅមូលដ្ឋាន និងធានាបាននូវភាពសុខដុមរមនា និងយុត្តិធម៌ក្នុងសង្គមជាតិ។

**មាត្រា២ ._**

ត្រូវបានបង្កើតអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដែលសរសេរជាអក្សរកាត់ថា **អ.ជ.ក.** មានបេសកកម្មដោះស្រាយក្រៅប្រព័ន្ធតុលាការនូវវិវាទរដ្ឋប្បវេណី វិវាទពាណិជ្ជកម្ម និងវិវាទដទៃទៀត តាមរយៈការសម្រុះសម្រួលផ្សះផ្សាវិវាទ ដោយផ្អែកតាមការព្រមព្រៀងរបស់ភាគីវិវាទ ឬតាមការស្នើសុំរបស់ភាគីវិវាទ ឬដែលភាគីវិវាទយល់ព្រមទទួលយកយន្តការសម្រុះសម្រួលផ្សះផ្សាវិវាទនេះ លើកលែងតែវិវាទដែលមិនអាចជាកម្មវត្ថុនៃការសម្រុះសម្រួលផ្សះផ្សា តាមការកំណត់របស់ច្បាប់។

## ជំពូកទី២
## សមាសភាព តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់ អ.ជ.ក.

**មាត្រា៣ ._**

**អ.ជ.ក.** មានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| - ឧបនាយករដ្ឋមន្ត្រី | ១ រូប | ប្រធាន |
| - រដ្ឋមន្ត្រីក្រសួងអធិការកិច្ច | | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ១ រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ១ រូប | អនុប្រធានប្រចាំការ |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ១ រូប | សមាជិក |
| - តំណាងក្រសួងពាណិជ្ជកម្ម | ១ រូប | សមាជិក |
| - តំណាងក្រសួងកិច្ចការនារី | ១ រូប | សមាជិក |
| - តំណាងក្រសួងធម្មការ និងសាសនា | ១ រូប | សមាជិក |
| - តំណាងគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា | ១ រូប | សមាជិក |
| - តំណាងក្រុមប្រឹក្សានីតិកម្មនិងយុត្តិធម៌ នៃក្រសួងយុត្តិធម៌ | ១ រូប | សមាជិក |
| - អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **អ.ជ.ក.** | | សមាជិក។ |

**អ.ជ.ក.** អាចមានសមាសភាពបន្ថែមផ្សេងទៀតជាអនុប្រធានឬសមាជិក តាមការចាំបាច់ ដែលជាឥស្សរជនតំណាងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ឬជ្រើសរើសចេញពីក្នុងចំណោមឥស្សរជនដែលមានបទពិសោធក្នុងកិច្ចការដោះស្រាយវិវាទ ឬជំនាញផ្នែកកិច្ចការច្បាប់ តុលាការ ឬកិច្ចការសង្គម។

សមាសភាពជាក់ស្តែងនិងសមាសភាពបន្ថែមនៃ **អ.ជ.ក.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៤ ._**

**អ.ជ.ក.** មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ដឹកនាំ សម្របសម្រួល និងអនុវត្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ តាមរយៈការសម្រុះសម្រួលផ្សះផ្សាវិវាទ

- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ គោលការណ៍ណែនាំ វិធានការនានា និងលិខិតបទដ្ឋានគតិយុត្ត សម្រាប់អនុវត្តយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន
- ដាក់ចេញនូវក្រមសីលធម៌ ក្រមប្រតិបត្តិ វិធាន និងលិខិតបទដ្ឋានគតិយុត្តនានា សម្រាប់អនុវត្តការសម្រុះសម្រួលផ្សះផ្សាវិវាទ ដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន
- ទទួលដោះស្រាយពាក្យបណ្តឹងនានា ដែលស្នើសុំឱ្យសម្រុះសម្រួលផ្សះផ្សាវិវាទក្រៅប្រព័ន្ធតុលាការ
- រៀបចំយន្តការ ដើម្បីចុះពិនិត្យ និងដោះស្រាយក្រៅប្រព័ន្ធតុលាការនូវវិវាទ ឬបណ្តឹងនានា នៅតាមមូលដ្ឋាន តាមរយៈការសម្រុះសម្រួលផ្សះផ្សា ដោយសហការជាមួយនឹងអាជ្ញាធរដែលមានការពាក់ព័ន្ធ
- តាមដាន ប្រមូលព័ត៌មាន និងវាយតម្លៃអំពីវឌ្ឍនភាពនៃការងារដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅព្រះរាជាណាចក្រកម្ពុជា ដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន
- ធ្វើរបាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលអំពីវឌ្ឍនភាពការងារ បញ្ហាប្រឈម និងសំណើវិធានការនានាទាក់ទងនឹងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រមុខរាជរដ្ឋាភិបាល។

**មាត្រា៥ ..**

**អ.ដ.ក.** មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ ដើម្បីគាំទ្រដល់កិច្ចដំណើរការរបស់ខ្លួន។

អគ្គលេខាធិការដ្ឋាននៃ **អ.ដ.ក.** ដឹកនាំដោយអគ្គលេខាធិការមួយរូប និងមានអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់។ អគ្គលេខាធិការ និងអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាននៃ **អ.ដ.ក.** ត្រូវតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់មុខតំណែងដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើសុំពីប្រធាន **អ.ដ.ក.**។

អគ្គលេខាធិការ និងអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាននៃ **អ.ដ.ក.** ត្រូវជ្រើសរើសចេញពីឥស្សរជន ឬមន្ត្រីរាជការ ដែលមានបទពិសោធបម្រើការងារផ្នែកច្បាប់ រដ្ឋបាល ឬហិរញ្ញវត្ថុ រយៈពេលយ៉ាងតិច ៥ឆ្នាំ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ **អ.ដ.ក.** ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៦ ..**

មន្ត្រីដែលបំពេញការងារនៅអគ្គលេខាធិការដ្ឋាននៃ **អ.ដ.ក.** គឺជាមន្ត្រីរាជការក្របខ័ណ្ឌនៃក្រសួងយុត្តិធម៌ ឬក្រសួងនិងស្ថាប័នដែលមានការពាក់ព័ន្ធផ្សេងទៀត។ អគ្គលេខាធិការដ្ឋាននៃ **អ.ដ.ក.** អាចមានមន្ត្រីជាប់កិច្ចសន្យាមួយចំនួនដើម្បីជួយការងារ តាមការចាំបាច់។

## ជំពូកទី៣
## កិច្ចដំណើរការរបស់ អ.ដ.ក.

**មាត្រា៧ ..**

**អ.ដ.ក.** ត្រូវរៀបចំឱ្យមានការប្រជុំជាទៀងទាត់រៀងរាល់ត្រីមាស ឬតាមការចាំបាច់ តាមការអញ្ជើញរបស់ប្រធាន **អ.ដ.ក.**។ កិច្ចប្រជុំរបស់ **អ.ដ.ក.** ត្រូវប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ប្រធាន **អ.ដ.ក.**។ ក្នុងករណីចាំបាច់ ប្រធាន **អ.ដ.ក.** អាចប្រគល់សិទ្ធិជូនអនុប្រធាន ដើម្បីដឹកនាំកិច្ចប្រជុំជំនួសបាន។

ប្រធាន **អ.ដ.ក.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័ន ឬអាជ្ញាធរពាក់ព័ន្ធ អ្នកឯកទេស ឬមន្ត្រីជំនាញចូលរួមប្រជុំ ឬផ្តល់យោបល់ តាមការចាំបាច់។

**មាត្រា៨ ..**

**អ.ដ.ក.** អាចរៀបចំឱ្យមានឯកសណ្ឋាន និងសញ្ញាសម្គាល់សម្រាប់ការអនុវត្តការងាររបស់មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ។ ឯកសណ្ឋាន និងសញ្ញាសម្គាល់ របស់មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ **អ.ដ.ក.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **អ.ដ.ក.**។

**អ.ដ.ក.** មានត្រាដោយឡែកសម្រាប់ប្រើប្រាស់ក្នុងកិច្ចដំណើរការការងាររបស់ខ្លួន។

**មាត្រា៩ ..**

ប្រធាន **អ.ដ.ក.** អាចបង្កើតក្រុមការងារសម្រុះសម្រួលដោះស្រាយវិវាទមួយចំនួនតាមការចាំបាច់ដោយសេចក្តីសម្រេច ដើម្បីសម្រុះសម្រួលផ្សះផ្សាវិវាទនានា ស្របតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ និងច្បាប់ជាធរមាន។ ក្រុមការងារសម្រុះសម្រួលដោះស្រាយវិវាទ ត្រូវដឹកនាំដោយមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ និងអាចមានសមាសភាពផ្សេងទៀតចូលរួម ដែលជាអ្នកជំនាញផ្នែកច្បាប់ ឬកិច្ចការសង្គម។

**មាត្រា១០ ..**

មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ **អ.ដ.ក.** អាចត្រូវបានជ្រើសរើសចេញពីក្នុងចំណោមមន្ត្រីរាជការក្របខ័ណ្ឌ ឬចេញពីក្នុងចំណោមសារការី មេធាវី និងអ្នកប្រកបវិជ្ជាជីវៈច្បាប់ផ្សេងទៀត ឬបុគ្គលផ្សេងទៀតដែលមានជំនាញផ្នែកច្បាប់ ឬជំនាញពាក់ព័ន្ធនឹងការដោះស្រាយវិវាទ។

មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ **អ.ដ.ក.** ត្រូវទទួលបាននីតិសម្បទាពី **អ.ដ.ក.** ដើម្បីអាចអនុវត្តមុខងាររបស់ខ្លួនស្របតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ។ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ **អ.ដ.ក.** ត្រូវធ្វើសច្ចាប្រណិធានដែលរៀបចំដោយក្រសួងយុត្តិធម៌ មុននឹងអនុវត្តមុខងាររបស់ខ្លួន។

បែបបទ នីតិវិធី និងគុណវុឌ្ឍិសម្រាប់ការផ្តល់នីតិសម្បទាដល់មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ត្រូវកំណត់ដោយ **អ.ដ.ក.**។

មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ **អ.ដ.ក.** ត្រូវទទួលបានការបណ្តុះបណ្តាលដែលរៀបចំដោយក្រសួងយុត្តិធម៌ លើជំនាញច្បាប់ ជំនាញដោះស្រាយវិវាទ ព្រមទាំងក្រមសីលធម៌វិជ្ជាជីវៈ និងក្រមប្រតិបត្តិ។

## ជំពូកទី៤
## កិច្ចដំណើរការនៃការសម្រុះសម្រួលដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ក្នុងក្របខ័ណ្ឌ អ.ដ.ក.

**មាត្រា១១ ..**

ការដោះស្រាយវិវាទនៅក្នុងក្របខ័ណ្ឌនៃ **អ.ដ.ក.** ត្រូវធ្វើឡើងតាមរយៈវិធីសម្រុះសម្រួលផ្សះផ្សា។

ក្នុងកិច្ចដំណើរការសម្រុះសម្រួលផ្សះផ្សាវិវាទ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ត្រូវផ្តល់ឱ្យភាគីវិវាទនូវឱកាសព្រមព្រៀងដោះស្រាយវិវាទដោយសន្តិវិធី និងដោយគ្មានការធ្វើការសម្រេចសេចក្តីដោយបង្ខំណាមួយឡើយ។ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ អាចផ្តល់មតិជាការវាយតម្លៃអំពីវិវាទ ស្នើនូវដំណោះស្រាយសម្រាប់វិវាទ និងផ្តល់យោបល់អំពីផលវិបាកដែលអាចកើតមានពីការព្រមព្រៀងបញ្ចប់វិវាទ។ ប៉ុន្តែ នៅក្នុងគ្រប់ករណីទាំងអស់ រាល់ដំណោះស្រាយចំពោះវិវាទត្រូវតែគោរពតាមឆន្ទៈយល់ព្រមដោយសេរី និងដោយស្ម័គ្រចិត្តពីភាគីវិវាទ។

វិវាទដែលជាកម្មវត្ថុនៃការសម្រុះសម្រួលផ្សះផ្សា ក្នុងសមត្ថកិច្ច **អ.ជ.ក.** រួមមាន វិវាទរដ្ឋប្បវេណី វិវាទពាណិជ្ជកម្ម និងវិវាទដទៃទៀត ដែលផ្អែកតាមច្បាប់ ការបញ្ចប់វិវាទទាំងនេះចំណុះឱ្យសេរីភាពនៃឆន្ទៈរបស់ភាគីវិវាទ។

ការសម្រុះសម្រួលផ្សះផ្សាវិវាទនៅក្នុងក្របខ័ណ្ឌនៃ **អ.ជ.ក.** មិនអាចធ្វើបានឡើយចំពោះបទល្មើសព្រហ្មទណ្ឌ លើកលែងតែច្បាប់អនុញ្ញាត។

**មាត្រា១២ ..**

**អ.ជ.ក.** អាចទទួលពិនិត្យ និងដោះស្រាយពាក្យបណ្ដឹងរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល ស្របតាមលក្ខខណ្ឌដូចមានចែងក្នុងព្រះរាជក្រឹត្យនេះ។

**អ.ជ.ក.** អាចទទួលបណ្ដឹងរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល ដោយផ្ទាល់ ឬតាមរយៈស្ថាប័នដែលមានការពាក់ព័ន្ធទាំងស្ថាប័នថ្នាក់ជាតិ និងស្ថាប័នថ្នាក់ក្រោមជាតិ។

**មាត្រា១៣ ..**

**អ.ជ.ក.** អាចទទួលពិនិត្យ និងដោះស្រាយនូវសំណុំរឿងវិវាទដែលបញ្ជូនពីសាលាជម្រះក្ដីជាន់ទាប ក្នុងករណីភាគីវិវាទណាមួយបង្ហាញឆន្ទៈឱ្យធ្វើការសម្រុះសម្រួលផ្សះផ្សាវិវាទរបស់ខ្លួន។ ក្រោយបញ្ចប់ការសម្រុះសម្រួលផ្សះផ្សាវិវាទ **អ.ជ.ក.** ត្រូវធ្វើរបាយការណ៍អំពីលទ្ធផលនៃការសម្រុះសម្រួលផ្សះផ្សាវិវាទទៅសាលាជម្រះក្ដីដែលបានបញ្ជូនសំណុំរឿងវិវាទនោះមក **អ.ជ.ក.** ដោយភ្ជាប់ជាមួយនូវសំណុំរឿង និងឯកសារពាក់ព័ន្ធ។

ក្នុងករណីដែលសំណុំរឿងវិវាទនោះមិនអាចដោះស្រាយបញ្ចប់ដោយការសម្រុះសម្រួលផ្សះផ្សាគ្នាបាន **អ.ជ.ក.** ត្រូវបញ្ជូនសំណុំរឿងវិវាទនោះទៅសាលាជម្រះក្ដីវិញ ដើម្បីបន្តចំណាត់ការដោះស្រាយស្របតាមច្បាប់ និងនីតិវិធីជាធរមាន។ ភាគីវិវាទក៏មានសិទ្ធិស្នើសុំទៅតុលាការ ដើម្បីបន្តចំណាត់ការនីតិវិធីលើសំណុំរឿងវិវាទបានផងដែរ ក្នុងករណីដែលភាគីវិវាទយល់ឃើញថា ការដោះស្រាយដោយការសម្រុះសម្រួលគ្នានៅ **អ.ជ.ក.** មិនអាចប្រព្រឹត្តទៅបាន។

បែបបទ និងនីតិវិធីនៃការបញ្ជូនសំណុំរឿងវិវាទរវាងសាលាជម្រះក្ដី និង **អ.ជ.ក.** ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**មាត្រា១៤ ..**

ការសម្រុះសម្រួលផ្សះផ្សាវិវាទក្នុងក្របខ័ណ្ឌ **អ.ជ.ក.** ត្រូវធ្វើឡើងដោយមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទដែលទទួលបានការចាត់តាំងពី **អ.ជ.ក.** ឬដោយក្រុមការងារសម្រុះសម្រួលដោះស្រាយវិវាទដែលទទួលបានការចាត់តាំងពី **អ.ជ.ក.** ឬដោយ **អ.ជ.ក.**។

នៅក្នុងការពិនិត្យ និងសម្រុះសម្រួលដោះស្រាយវិវាទ **អ.ជ.ក.** ឬក្រុមការងារសម្រុះសម្រួលដោះស្រាយវិវាទរបស់ **អ.ជ.ក.** ឬមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ អាចកោះអញ្ជើញភាគីវិវាទ សាក្សី ឬបុគ្គលពាក់ព័ន្ធផ្សេងទៀត ណែនាំឱ្យភាគីវិវាទបញ្ជាក់ពីការទាមទារ ឬផ្ដល់ព័ត៌មានបន្ថែមលើការទាមទារ ឬស្រាវជ្រាវព័ត៌មានផ្សេងទៀតដែលទាក់ទងនឹងវិវាទ ដោយយោងតាមការចាំបាច់ ដើម្បីជាមូលដ្ឋានក្នុងការដោះស្រាយវិវាទ។ ភាគីវិវាទអាចត្រូវបានតំណាងដោយអ្នកតំណាងដោយអាណត្តិ ឬអាចអមដោយមេធាវី ឬអ្នកប្រឹក្សាយោបល់របស់ខ្លួន តាមការចាំបាច់។

**មាត្រា១៥ ..**

ក្នុងករណីភាគីវិវាទព្រមព្រៀងសះជាបញ្ចប់វិវាទនឹងគ្នា មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ឬក្រុមការងារសម្រុះសម្រួលដោះស្រាយវិវាទ ឬ **អ.ជ.ក.** ដែលបានទទួលចាត់ការករណីនេះ ត្រូវចេញកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ។ ក្នុងករណីដែលកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទធ្វើឡើងដោយមិនត្រឹមត្រូវស្របតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ និងបទប្បញ្ញត្តិច្បាប់ជាធរមាន ភាគីវិវាទមានសិទ្ធិប្ដឹងតវ៉ាទៅ **អ.ជ.ក.** ក្នុងរយៈពេល ៣០ថ្ងៃ គិតពីថ្ងៃធ្វើកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ។ ក្នុងករណីមិនមានបណ្ដឹងតវ៉ាក្នុងរយៈពេល ៣០ថ្ងៃខាងលើ ឬបណ្ដឹងតវ៉ាត្រូវបានសម្រេចបដិសេធដោយ **អ.ជ.ក.** កំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ ត្រូវចាត់ទុកថាធ្វើឡើងត្រឹមត្រូវស្របតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ។

កំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទដែលធ្វើឡើងត្រឹមត្រូវស្របតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ មានតម្លៃគតិយុត្តដូចលិខិតយថាភូត និងត្រូវទុកជាបន្ទាល់ដែលតុលាការត្រូវជឿរហូតដល់មានភស្តុតាងផ្ទុយ ឬមានភស្តុតាងដែលបង្ហាញអំពីការក្លែងបន្លំ ឬកិច្ចការៈដទៃទៀតនៅក្នុងកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទនោះ។ កំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទនេះ មានអានុភាពអនុវត្តដូចគ្នានឹងសាលក្រមស្ថាពររបស់តុលាការ និងត្រូវចាត់ទុកជាលិខិតអនុវត្ត ដូចមានចែងក្នុងចំណុច ឈ នៃកថាខណ្ឌទី២ នៃមាត្រា៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ការស្នើសុំអនុវត្តដោយបង្ខំនូវកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ ត្រូវធ្វើឡើងស្របតាមនីតិវិធីច្បាប់ជាធរមាន។ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ឬក្រុមការងារសម្រុះសម្រួលដោះស្រាយវិវាទ ឬ **អ.ជ.ក.** ដែលចេញកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ ត្រូវផ្ដល់រូបមន្តអនុវត្តចំពោះកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ តាមការស្នើសុំ។ **អ.ជ.ក.** ត្រូវចាត់នីតិវិធីចាំបាច់នានា ដើម្បីធានាដល់ការអនុវត្តកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទដែលធ្វើឡើងត្រឹមត្រូវស្របតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ។

ប្រសិនបើខ្លឹមសារនៃកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទនេះ ផ្ទុយនឹងបទប្បញ្ញត្តិដែលអនុវត្តដោយបង្ខំណាមួយ ឬសណ្ដាប់ធ្នាប់សាធារណៈ ឬទំនៀមទម្លាប់ល្អនៃព្រះរាជាណាចក្រកម្ពុជា ភាគីដែលមានការពាក់ព័ន្ធអាចប្រើប្រាស់សិទ្ធិរបស់ខ្លួន ដើម្បីប្ដឹងទៅសាលាដំបូងដែលមានសមត្ថកិច្ច ដោយអនុវត្តស្របតាមច្បាប់ និងនីតិវិធីជាធរមាន។

កំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ មិនត្រូវធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់របស់តតិយជនឡើយ។ ក្នុងករណីនេះ តតិយជនអាចប្រើប្រាស់សិទ្ធិប្ដឹងទៅសាលាដំបូងដែលមានសមត្ថកិច្ច ដើម្បីការពារផលប្រយោជន៍របស់ខ្លួន ស្របតាមច្បាប់និងនីតិវិធីជាធរមាន។

**មាត្រា១៦ ..**

បែបបទនិងនីតិវិធីលម្អិតនៃការសម្រុះសម្រួលផ្សះផ្សាវិវាទក្នុងក្របខ័ណ្ឌ **អ.ជ.ក.** ព្រមទាំងទម្រង់និងខ្លឹមសារសំខាន់ៗ នៃកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ ត្រូវកំណត់ដោយ **អ.ជ.ក.**។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចចេញសេចក្ដីណែនាំ ដើម្បីធានាដល់ការអនុវត្តនៃកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ ដែលត្រូវបានធ្វើឡើងក្នុងក្របខ័ណ្ឌនៃ **អ.ជ.ក.** ស្របតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ និងច្បាប់ជាធរមាន។

**មាត្រា១៧.-**

នៅពេលចុះអនុវត្តការងាររបស់ខ្លួន មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ឬក្រុមការងារសម្រុះសម្រួលដោះស្រាយវិវាទនៃ **អ.ជ.ក.** ត្រូវមានលិខិតបញ្ជាបេសកកម្ម ព្រមទាំងត្រូវប្រកាន់ខ្ជាប់នូវក្រមប្រតិបត្តិ និងក្រមសីលធម៌ ដែលកំណត់ដោយ **អ.ជ.ក.**។

ក្នុងក្របខ័ណ្ឌនៃការអនុវត្តការងាររបស់ខ្លួន មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ឬក្រុមការងារសម្រុះសម្រួលដោះស្រាយវិវាទ មានសិទ្ធិស្នើសុំកិច្ចសហការពីស្ថាប័ន ឬអាជ្ញាធរពាក់ព័ន្ធ តាមការចាំបាច់។

**មាត្រា១៨.-**

មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ មិនទទួលខុសត្រូវឡើយចំពោះការអនុវត្តមុខងាររបស់ខ្លួន ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ប៉ុន្តែ ក្នុងការអនុវត្តមុខងាររបស់ខ្លួន មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទដែលប្រើប្រាស់សិទ្ធិអំណាចដោយរំលោភបំពាន ក្នុងចេតនាទុច្ចរិតធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍ស្របច្បាប់ ឬធ្វើឱ្យខូចខាតទ្រព្យសម្បត្តិរបស់បុគ្គលដទៃ ត្រូវទទួលខុសត្រូវតាមច្បាប់ចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត។

## ជំពូកទី៥
## ប្រភពធនធានរបស់ អ.ជ.ក.

**មាត្រា១៩.-**

**អ.ជ.ក.** មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិជាកញ្ចប់ថវិកាដោយឡែក នៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងយុត្តិធម៌។

**អ.ជ.ក.** មានសិទ្ធិទទួល គ្រប់គ្រង និងចាត់ចែងមូលនិធិ និងអំណោយដែលបានមកពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការអន្តរជាតិ ដៃគូអភិវឌ្ឍ និងប្រភពស្របច្បាប់ផ្សេងទៀត សម្រាប់ដំណើរការការងាររបស់ខ្លួន។

**មាត្រា២០.-**

ប្រធាន អនុប្រធាន និងសមាជិកនៃ **អ.ជ.ក.** ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីនៃអគ្គលេខាធិការដ្ឋាននៃ **អ.ជ.ក.** ទទួលបានប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងទៀត សម្រាប់ការបំពេញការងាររបស់ខ្លួន។

មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ព្រមទាំងសមាជិកនៃក្រុមការងារសម្រុះសម្រួលដោះស្រាយវិវាទនៃ **អ.ជ.ក.** ទទួលបានប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងទៀត សម្រាប់ការបំពេញការងាររបស់ខ្លួន។

ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងទៀត ក្នុងក្របខ័ណ្ឌ **អ.ជ.ក.** ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា២១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២២.-**

សម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១១រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ២០២៣

ពរស.២៣១១.២៥០០

**នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**